# សេចក្តីជូនដណឹងលេខ ០០៧
# ស្តីពីការបន្តអនុវត្តន៍កាតព្វកិច្ច
# ហ្វឹកហ្វឺនកូនជាង និងការធ្វើតេ
# ស្តលើកម្មករចាស់ចំពោះសហា
# គ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ដែល
# ពុំទាន់បានចាប់ផ្តើមអនុវត្តក្នុង
# ឆ្នាំ ២០០១

www.ekasar.com

00243

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ......០៧......សកបយ

ភ្នំពេញ ថ្ងៃទី២៦ ខែ ០៣ ឆ្នាំ២០០២

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបន្តអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង និងការធ្វើតេស្តលើកម្មករចាស់ ចំពោះសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ដែលពុំទាន់បានចាប់ផ្តើមអនុវត្តក្នុងឆ្នាំ ២០០១

យោងប្រកាសលេខ ០០៤ សកបយ ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ២០០០ ស្តីពីការហ្វឹកហ្វឺនកូនជាង សេចក្តីណែនាំលេខ ០០៣ សកបយ ចុះថ្ងៃទី ០៣ ខែមិនា ឆ្នាំ២០០១ ស្តីពីនីតិវិធីក្នុងការអនុវត្តន៍ប្រកាសលេខ ០០៤ និងសេចក្តីជូនដំណឹងលេខ ៣៥ សកបយ.បទ ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការសំរបសំរួលថ្លៃផលិតសំណុំបែបបទការហ្វឹកហ្វឺនកូនជាង ការធ្វើតេស្តលើកូនជាង និងកម្មករចាស់ វិញ្ញាបនប័ត្រ និងប័ណ្ណទទួលស្គាល់ការតមុខ-ជំនាញវិជ្ជាជីវៈ ។

ក្នុងគោលបំណងជំរុញការអនុវត្តន៍ប្រកាស និងបញ្ញត្តិដូចបានពោលខាងលើ ចប់សព្វគ្រប់សំរាប់កាតព្វកិច្ចឆ្នាំ ២០០១ បានជោគជ័យ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមធ្វើការក្រើនរំលឹកដល់បណ្តាសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនមួយចំនួន ដែលពុំទាន់បានបំពេញកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង និងធ្វើតេស្តលើកម្មករចាស់ ត្រូវចាប់ផ្តើម និងបន្តបំពេញកាតព្វកិច្ចនេះអោយពេញលេញ និងចប់សព្វគ្រប់តាមនីតិវិធីដូចតទៅ ៖

១- សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ដែលបានផ្ញើបញ្ជីឈ្មោះកម្មករចាស់ ដែលសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនធ្លាប់បានហ្វឹកហ្វឺនមុនពេលចេញប្រកាសលេខ០០៤ សកបយ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០០ ស្តីពីការហ្វឹកហ្វឺនកូនជាង អាចមកទំនាក់ទំនងបំពេញកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង ឬធ្វើតេស្តលើកម្មករចាស់ អាស្រ័យទៅលើតម្រូវការចាំបាច់របស់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ។

២- សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនដែលពុំធ្លាប់ធ្វើការហ្វឹកហ្វឺនកូនជាង មុនពេលចេញប្រកាសលេខ ០០៤ សកបយ ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ២០០០ ស្តីពីការហ្វឹកហ្វឺនកូនជាង ឬមិនបានផ្ញើបញ្ជីឈ្មោះកម្មករចាស់ ដែលសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនធ្លាប់ធ្វើការហ្វឹកហ្វឺនមកនាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈ និងទីផ្សារការងារ នៃ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មុនថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០១ តាមសេចក្តីជូនដំណឹងលេខ ០០៣ សកបយចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០១ ស្តីពីនីតិវិធីក្នុងការអនុវត្តន៍ប្រកាសលេខ ០០៤ សកបយ ត្រូវមកចំនួនទំនាក់ទំនងដើម្បីបំពេញកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង ជាកំហិត ។

៣- ចំពោះសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនដែលបោះទីតាំងនៅតាមខេត្ត-ក្រុងនានា ហើយពុំទាន់បានទទួល

www.ekasar.com

ឬ អនុវត្តសេចក្តីណែនាំលេខ ០០៣ សកបយ ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០១ ស្តីពីនីតិវិធីក្នុងការអនុវត្តន៍ប្រកាសលេខ ០០៤ ក្នុងចំណុចទី ២ ក្រសួងអនុញ្ញាតអោយធ្វើបញ្ជីឈ្មោះកម្មករចាស់ដែលសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនធ្លាប់បានហ្វឹកហ្វឺន មុនពេលចេញប្រកាសលេខ ០០៤ សកបយ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០០ ស្តីពីការហ្វឹកហ្វឺនកូនជាង ទៅនាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈ និងទីផ្សារការងារ ។

៤- សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនដូចមានចែងក្នុងចំនុចទី ១ ចំនុចទី ២ និងចំនុចទី ៣ ខាងលើត្រូវប្រញាប់ប្រញាល់មកទំនាក់ទំនងដើម្បីបំពេញកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង ឬធ្វើតេស្តលើកម្មករចាស់សំរាប់ឆ្នាំ ២០០១ នៅនាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈ និងទីផ្សារការងារ នៃ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ឬនៅតាមមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុង យ៉ាងយូរបំផុតត្រឹមថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០០២ ជាកំហិត ។

៥- ក្នុងករណីសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនណាពុំព្រមអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង ការធ្វើតេស្តលើកម្មករចាស់សំរាប់ឆ្នាំ ២០០១ ឬធ្វើឈ្មោះកម្មករដែលសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនធ្លាប់បានហ្វឹកហ្វឺនកន្លងមកអោយបានទាន់ពេលវេលាកំណត់ដូចមានចែងក្នុងចំណុចទី ៤ នៃសេចក្តីជូនដំណឹងនេះ នឹងត្រូវទទួលការផាកពិន័យដូចមានចែងក្នុងមាត្រាទី ៣៦៣ នៃច្បាប់ស្តីពីការងារ និងត្រូវបង់ពន្ធអាករជំនួសការហ្វឹកហ្វឺនកូនជាងតាមចំនួនដូចមានចែងក្នុងប្រការ ៨ នៃប្រកាសលេខ ០០៤ សកបយ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០០ ស្តីពីការហ្វឹកហ្វឺនកូនជាង ។

ចំពោះពត៌មានបន្ថែម សូមទំនាក់ទំនងជាមួយនាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈ និងទីផ្សារការងារ នៃ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដែលមានអាស័យដ្ឋានអាគារលេខ២៨ ផ្លូវលេខ១៨៤ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឬទំនាក់ទំនងតាមទូរស័ព្ទលេខ ០២៣-៧២២ ៩៩១ ០១២-៨៤៧ ២៦៤ និង ០១១-៩៧៤ ៨១០ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាសង្ឃឹម និងជឿជាក់ថា នាយកឬម្ចាស់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ទាំងអស់ នឹងរៀបចំដំណើរការអនុវត្តន៍តាមសេចក្តីជូនដំណឹងនេះអោយបានទាន់ពេលវេលាកំណត់ និងមានប្រសិទ្ធិភាពខ្ពស់ជាពុំខានឡើយ ។

**អ៊ិត សំហេង**

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជ្រាប"
- អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- គ្រប់មន្ទីរ សកបយ ខេត្ត-ក្រុង "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- សមាគមនិយោជក "ដើម្បីជ្រាប"
- សហជីព "ដើម្បីជ្រាប"
- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ